# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ឥសីលើគម្ពីរដើររកអ្នកមានបុណ្យ ។

www.hoksavann.org

ថ្ងៃទី១៤ ឧសភា ២០១២



អ្នកប្រាជ្ញបុរាណខ្មែរបានពិនិត្យឃើញស្ថានការណ៍នៅប្រទេសកម្ពុជាពីអតីតកាល ឆ្លុះបញ្ចាំងទៅអនាគតកាល បានបង្ហាញទស្សនៈឲ្យខ្មែរទូទៅពិចារណាតាមរយៈរឿងរ៉ាវមួយ ដែលលោកឲ្យឈ្មោះថា ពុទ្ធទំនាយ ។ ពុទ្ធទំនាយនោះដំណាលថា ថ្ងៃមួយលោកតាឥសីមួយអង្គបានលីគម្ពីរដើររកអ្នកមានបុណ្យ ។ ដើរយូរបន្តិចបានជួបភិក្ខុមួយអង្គ កំពុងភាវនាធម៌នៅភ្នំត្បែង ។ ពេលនោះលោកតាឥសីបានបើកគម្ពីរមើលឃើញថា ភិក្ខុនេះហើយជាព្រះបាទធម្មិក ។ ថាតែប៉ុណ្ណោះស្រាប់តែផុសឡើង សេនាដៃឯកឆ្វេងស្តាំ ព្រមទាំងប្រដាប់សំរាប់រាជ្យ ។ បន្ទាប់មកទើបនាំគ្នាហែហមភិក្ខុអង្គនោះទៅទន្លេបួនមុខ រាជធានីភ្នំពេញប្រទេសកម្ពុជា ទៅជួបនឹងធម្មិកទាំង៨ទិសដែលកំពុងច្បាំងគ្នា ដណ្តើមធម្មិករៀងៗខ្លួន ។ ធម្មិកទាំង៨ទិសកំពុងស្តាប់ឱវាទភិក្ខុមកពីភ្នំត្បែង ដែលឃាត់កុំឲ្យច្បាំងគ្នាឡើយ ថែមទាំងបាញ់ចំរុះមកលើភិក្ខុអង្គនោះថែមទៀត ។ ប៉ុន្តែសដែលបាញ់នោះ ក្លាយជាកម្រងផ្កាថ្វាយព្រះអង្គទៅវិញ ។ លុះឃើញដូចនេះ ធម្មិកទាំង៨ទិសយល់យ៉ាងច្បាស់ថា ភិក្ខុអង្គនេះជាអ្នកមានបុណ្យ ជាព្រះបាទធម្មិកពិតមែន ពុំមែនពួកយើងទាំង៨ទិសនេះឡើយ ទើបសុខចិត្តថ្វាយបង្គំចុះចាញ់ ។

តាមដំណាលរឿងនេះថា ធម្មិកទាំង៨ទិសនេះមកពីទិសទាំង៨ គឺទិសធំ៤និងទិសតូច៤ តាំងខ្លួនជាធម្មិក គឺជាអ្នកមានបុណ្យ ត្រូវតែខ្មែរគ្រប់ឋានៈគោរពបូជា ។ តាមព្រះពុទ្ធសាសនា ពាក្យថា «ធម្មិក» ប្រែថាអ្នកមានធម៌ ។ បើតាមន័យនេះ ធម្មិកទាំង៨ទិសដែលច្បាំងគ្នាប្រកបដោយអំពើហិង្សាបែបនេះ ពុំមែនជាធម្មិកឡើយ គឺជាធម្មិកក្លែងក្លាយ ។ ធម្មិកក្លែងក្លាយនេះហាក់ដូចជាចាស់បូរាណខ្មែរប្រៀបមកមន្ត្រីរាជការគ្រប់តំណែង ដែលមិនបានបំពេញមុខងារនាទីរបស់ខ្លួនឲ្យបានល្អត្រឹមត្រូវ ប្រព្រឹត្តអំពើពុករលួយ រំលោភច្បាប់ បៀតបៀនប្រជាពលរដ្ឋ ។ បើរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) វិញ មិនត្រឹមតែរបបកុម្មុយនិស្តផ្តាច់ការប៉ុណ្ណោះទេ ថែមទាំងជារបបឃោរឃៅព្រៃផ្សៃ ជាឃាតករសម្លាប់ប្រជាពលរដ្ឋរបស់ខ្លួន ដែលផ្ទុយពីពួកនេះអះអាងថា ខ្លួនជាអ្នកស្នេហាជាតិ ស្នេហាប្រជាជន របបរបស់ខ្លួនជារបបស្អាតស្អំ បំរើយុត្តិធម៌ក្នុងសង្គម ពោលគឺតាំងខ្លួនជាព្រះបាទធម្មិកហ្នឹងឯង ។ តាមព្រះពុទ្ធសាសនា ការវិនិច្ឆ័យមនុស្សល្អអាក្រក់ ពុំមែនវិនិច្ឆ័យពាក្យសំដីនិយាយនោះឡើយ គឺស្ថិតនៅលើអំពើដែលធ្វើ ។ បានសេចក្តីថា បើគេប្រព្រឹត្តល្អដោយកាយវាចាចិត្ត គេជាមនុស្សល្អ ។ ផ្ទុយទៅវិញ បើគេប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គេជាមនុស្សអាក្រក់ ។ ក្នុងន័យនេះ ប្រទេសកម្ពុជាកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស ជ្រើសរើសអ្នកកាន់ការរដ្ឋតាមរយៈការបោះឆ្នោត ។ ដូច្នេះមុននឹងបោះឆ្នោតឲ្យគណបក្សណាមួយ ត្រូវពិនិត្យមើលប្រវត្តិនៃអ្នកដឹកនាំគណបក្ស ពិនិត្យមើលកម្មវិធីនយោបាយជាដើម ។ ពុំមែនបោះឆ្នោតឲ្យគណបក្សណាមួយ ដោយការខ្លាច ដោយការគំរាមកំហែង ឬដោយទទួលអំណោយ និងដោយការលួងលោមឡើយ ។

ភិក្ខុមកពីភ្នំត្បែង ជានិមិត្តរូបនៃអ្នកដឹកនាំល្អ ការពារយុត្តិធម៌ និងអំពើល្អគ្រប់យ៉ាង ។ បើពោលក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះជាអ្នកសំរេចធម៌ជាន់ខ្ពស់ គោរពធម៌វិន័យ ជាបណ្ឌិតឬសប្បុរស ដែលមនុស្សសត្វទូទៅគួរគោរពបូជា និងស្តាប់ឱវាទ ។ សប្បុរសរស់នៅទីណា ទីនោះនឹងបានសេចក្តីសុខ ។ ពាក្យថា អ្នកមានបុណ្យ គឺអ្នកដែលបានកសាងល្អពីដើមមក ពុំមែនបុណ្យកើតឡើងឯងដោយមិនបានកសាងឡើយ ។ ដូចពាក្យថា បារមី ដែលប្រែថា គុណជាតិជាគ្រឿងដល់ត្រើយ គឺព្រះនិញ្វន ដោយការកសាង បើធ្វើទាន ហៅថាទានបារមី បើរក្សាសីល ហៅថាសីលបារមីជាដើម ។ ដូច្នេះបើចង់បានបារមីត្រូវកសាង ។ ផ្ទុយពីអ្នកខ្លះ តាំងខ្លួនជាអ្នកមានបុណ្យ តាំងខ្លួនជាព្រះសេអារ្យមេត្រី រហូតតាំងខ្លួនជាព្រះពុទ្ធអង្គ ឲ្យគេគោរពបូជា ដើម្បីលាភសក្ការៈ ។ នេះជាការបោកបញ្ឆោតមនុស្សល្ងង់ខ្លៅឲ្យជឿ ប៉ុន្តែមិនអាចបោកលោកអ្នកសប្បុរស ឬបណ្ឌិតបានឡើយ ។ កាលណាមានអំពើនេះកើតឡើង នាំឲ្យអ្នកសិក្សាតិចអំពីព្រះពុទ្ធសាសនា នឹងមានការភ័ន្តច្រឡំអំពីធម៌វិន័យរបស់ព្រះពុទ្ធ ។ មិនគួរឲ្យអំពើនេះកើតឡើងតទៅទៀតឡើយ ដើម្បីឲ្យព្រះពុទ្ធសាសនាមានភាពបរិសុទ្ធ ។៚

*　　　*

*